ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ៤៥៥ សនគ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ២០១១

# ប្រកាស

## ស្តីពី

## ការធ្វើប្រតិភូកម្មមុខងារ នៃវិស័យសុខាភិបាល ជូនការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុក គោលដៅ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត ០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញច្បាប់ ស្តីពីការ គ្រប់គ្រងលើការប្រកបវិជ្ជាជីវៈ ឯកជនក្នុងវិស័យ វេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/ ១១០០/១០ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០០

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល

-បានឃើញសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ

-បានឃើញប្រកាសលេខ ០០១៤ អបស/ ឱអបស ចុះថ្ងៃទី ១៣ ខែ មករា ២០០៩ ស្តីពីបែបបទ និងល័ក្ខខ័ណ្ឌ ក្នុងការសុំបើក ឬបិទ ឬសុំប្តូរទីតាំង នៃគ្រឹះស្ថានលក់ឱសថ

-បានឃើញប្រកាសលេខ ០៣៤ អបស/មព ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការកែសម្រួលបែបបទ និងល័ក្ខខ័ណ្ឌបច្ចេកទេសក្នុងការសុំបើកឬបិទ សុំកែទ្រង់ទ្រាយ ឬប្តូរទីតាំង នៃសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន

-បានឃើញប្រកាសលេខ ៩២៨ ប្រក ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុក ខ័ណ្ឌគោលដៅ របស់ក្រសួងមហាផ្ទៃ

-បានឃើញសេចក្តីសម្រេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ សាកល្បងនៅស្រុកសៀមរាប ខេត្តសៀមរាប ស្រុកបាត់ដំបង ខេត្តបាត់ដំបង

-បានឃើញសេចក្តីសម្រេចលេខ ១៣២៩ សសរ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១០ របស់ក្រសួងមហាផ្ទៃ ស្តីពីការកំណត់ក្រុងគោលដៅ នៃគំពេងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ សម្រាប់អនុវត្តក្នុងឆ្នាំទីពីរ (២០១០-២០១១)

-បានឃើញលិខិតលេខ ៦៤ អ.រ.ម ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដោយមានចំណារឯកភាពរបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្តីពីការផ្លាស់ប្តូរឈ្មោះ ស្រុក ខ័ណ្ឌគោលដៅ នៃគំពេងការិយាល័យច្រកចេញចូលតែមួយ

# សម្រេច

ប្រការ១.-

ត្រូវបានធ្វើប្រតិភូកម្មមុខងារ ពីក្រសួងសុខាភិបាល ជូនដល់ការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុកគោលដៅ ក្នុងការចេញលិខិតអនុញ្ញាត សុំបើក ឬ បិទ ឬ ប្តូរទីតាំង និង បន្តសុពលភាពសេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ។

ប្រការ២.-

ការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុកគោលដៅ ដែលត្រូវទទួលមុខងារ ក្នុងការចេញលិខិតអនុញ្ញាត ដូចចែងក្នុងប្រការ ១ មាន ៖

| | |
|---|---|
| ១-ក្រុងសៀមរាប | នៃខេត្តសៀមរាប |
| ២-ក្រុងប៉ោយប៉ែត | នៃខេត្តបន្ទាយមានជ័យ |
| ៣-ក្រុងបាត់ដំបង | នៃខេត្តបាត់ដំបង |
| ៤-ក្រុងពោធិសាត់ | នៃខេត្តពោធិសាត់ |
| ៥-ក្រុងកំពង់ឆ្នាំង | នៃខេត្តកំពង់ឆ្នាំង |
| ៦-ក្រុងច្បារមន | នៃខេត្តកំពង់ស្ពឺ |
| ៧-ក្រុងតាខ្មៅ | នៃខេត្តកណ្តាល |
| ៨-ក្រុងស្ទឹងសែន | នៃខេត្តកំពង់ធំ |
| ៩-ក្រុងសួង | នៃខេត្តកំពង់ចាម |
| ១០-ក្រុងក្រចេះ | នៃខេត្តក្រចេះ |
| ១១-ក្រុងបានលុង | នៃខេត្តរតនគីរី |
| ១២-ក្រុងបាវិត | នៃខេត្តស្វាយរៀង |
| ១៣-ក្រុងកំពត | នៃខេត្តកំពត |
| ១៤-ក្រុងដូនកែវ | នៃខេត្តតាកែវ |
| ១៥-ក្រុងព្រះសីហនុ | នៃខេត្តព្រះសីហនុ |
| ១៦-ក្រុងខេមរភូមិន្ទ | នៃខេត្តកោះកុង |
| ១៧-ស្រុកពាមរក៍ | នៃខេត្តព្រៃវែង ។ |

ប្រការ៣.-

សេវាឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលត្រូវធ្វើប្រតិភូកម្មជូនការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុកគោលដៅ ក្នុងការចេញលិខិតអនុញ្ញាត មាន ៖

-បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះមុននឹងក្រោយសម្រាល គ្រប់គ្រងដោយឆ្មប ដែលមានកំរិតបរិញ្ញាបត្រឆ្មប ឬ សញ្ញាបត្រសមមូលឡើងទៅ ទទួលស្គាល់ដោយក្រសួងសុខាភិបាល ។

-បន្ទប់ព្យាបាលដោយចលនា គ្រប់គ្រងដោយ អ្នកព្យាបាលដោយចលនា ដែលមានកំរិត បរិញ្ញាបត្ររងព្យាបាលដោយចលនា ឬ សញ្ញាបត្រសមមូលឡើងទៅ ទទួលស្គាល់ដោយក្រសួងសុខាភិបាល ។

-បន្ទប់ថែទាំជំងឺ គ្រប់គ្រងដោយគិលានុបដ្ឋាក ដែលមានកំរិត បរិញ្ញាបត្ររងគិលានុបដ្ឋាក ឬ សញ្ញាបត្រសមមូលឡើងទៅ ទទួលស្គាល់ដោយក្រសួងសុខាភិបាល ។

-ឱសថស្ថានរង គ្រប់គ្រងដោយ ឱសថការីមធ្យម ដែលមានសញ្ញាបត្រ ទទួលស្គាល់ដោយក្រសួងសុខាភិបាល ។

ប្រការ៤.-

មន្ត្រីទទួលបន្ទុកបច្ចេកទេសសុខាភិបាល ត្រូវរៀបចំគំរូបែបបទផ្សេងៗ រួមទាំងឯកសារពាក់ព័ន្ធ សម្រាប់ការចេញលិខិតអនុញ្ញាតទៅតាមប្រភេទសេវាសុខាភិបាលដូចចែងក្នុងប្រការ៣ ។

ប្រការ៥.-

ការអនុវត្តលើគំរូបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការចេញលិខិតអនុញ្ញាត របស់ការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុកគោលដៅ របស់មន្ត្រីជំនួយការ អភិបាលក្រុង ស្រុកគោលដៅ ត្រូវកំណត់ដោយសេចក្តីណែនាំមួយដោយឡែក របស់ក្រសួងសុខាភិបាល ។

ប្រការ៦.-

សាលាក្រុង ស្រុកគោលដៅ មានការិយាល័យច្រកចេញចូលតែមួយ ត្រូវធ្វើលិខិតចម្លង ស្តីពីការផ្តល់លិខិតអនុញ្ញាត ដូចចែងក្នុងប្រការ១ និង ផ្តល់របាយការណ៍ស្ថិតិ ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ មកក្រសួងសុខាភិបាល តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ប្រការ៧.-

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលខេត្តពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ម៉ម_ប៊ុនហេង

កន្លែងទទួល:

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យក្រសួងសុខាភិបាល
-សាលាខេត្តពាក់ព័ន្ធ
-ដូចប្រការ៧
-ឯកសារ-កាលប្បវត្តិ